ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លេខ :...០៩២.......អ.ជ.ប.ជ.អ

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី១ ឆ្នាំ២០២១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២១ បានដំណើរការរយៈពេលមួយព្រឹកពេញ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ តាមបណ្តាញវីដេអូ កម្មវិធី ZOOM ដោយមានការចូលរួមពី ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន កាកបាទក្រហមកម្ពុជា រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការ UNAIDS និងអង្គការសង្គមស៊ីវិលចំនួន៧ សរុបចំនួន១១០នាក់។

អង្គប្រជុំទាំងមូល បានធ្វើការគោរពថ្លែងនូវអំណរគុណប្រកបដោយកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាពក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយនៃមេរោគកូវីដ-១៩ ដោយរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សុខុមាលភាពសង្គមរបស់ប្រទេសកម្ពុជាបានយ៉ាងរឹងមាំ។ វិធានការដ៏មានតម្លៃនេះ បានចូលរួមវិភាគទានដ៏ធំធេងក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលតាមរយៈលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីផងដែរ។

អង្គប្រជុំក៏បានថ្លែងអំណរគុណ និងកោតសរសើរផងដែរចំពោះគ្រប់ស្ថាប័នទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទោះស្ថិតក្នុងស្ថានភាពដ៏លំបាកនៃការរាតត្បាតពីមេរោគកូវីដ-១៩ក៏ដោយ។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់ បានប្តេជ្ញាបន្តនូវឆន្ទៈរួមគ្នាក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ឱ្យ

បានជោគជ័យ តាមរយៈការធ្វើឱ្យសម្រេចនូវគោលនយោបាយសូន្យបី (សូន្យនៃការឆ្លងមេរោគអេដស៍ថ្មី សូន្យនៃការមាក់ងាយនិងរើសអើង និងសូន្យនៃការស្លាប់ដោយសារជំងឺអេដស៍) និងគោលដៅយុទ្ធសាស្ត្រ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ (៩៥%នៃអ្នកដែលផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពួកគេ ៩៥%នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យហើយបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៩៥% នៃអ្នកដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន ដែលលែងជាគ្រោះគំរាមកំហែងដល់អ្នកផ្ទុកមេរោគអេដស៍)។

ក្នុងដំណើរឆ្ពោះទៅកាន់ការសម្រេចគោលដៅ៩៥ទីមួយ អង្គប្រជុំបានយកចិត្តទុកដាក់រួមគ្នាផ្តោតលើការស្វែងរកករណីឆ្លងនិងបង្ការការចម្លងមេរោគអេដស៍ ក្នុងចំណោមប្រជាជនគន្លឹះ ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមអ្នកចាក់គ្រឿងញៀន។

ក្នុងគោលបំណងសម្រេចនូវឆន្ទៈខាងលើ កិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ ៖

១. បន្តអនុវត្ត និងតាមដានត្រួតពិនិត្យដោយម៉ឺងម៉ាត់នូវលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយនៅថ្នាក់ជាតិដឹកនាំដោយប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដឹកនាំដោយប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត។

២. ស្នើក្រសួងមហាផ្ទៃ ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ឱ្យបានទូទាំងប្រទេស ស្របតាមអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣. ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ថវិកាបន្ថែមយ៉ាងតិច ៨០.០០០.០០០រៀល (ប៉ែតសិបលានរៀល) ក្នុងមួយឆ្នាំសម្រាប់រាជធានី ខេត្តនីមួយៗ ជាពិសេសរាជធានីភ្នំពេញ បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ដែលជារាជធានី ខេត្ត បានចុះហត្ថលេខាចូលរួមអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cities Initiative) កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ តាមសេចក្តីប្រកាសទីក្រុងប៉ារីស នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីឱ្យរាជធានី ខេត្តមានលទ្ធភាពសម្រេចសូចនាករតាមកាលកំណត់។

៤. ផ្តល់អនុសាសន៍ដល់គ្រប់រាជធានី ខេត្ត ឱ្យចាប់ផ្តើមម្ចាស់ការទទួលខុសត្រូវអនុវត្តពេញលេញនូវភារកិច្ចគ្រប់គ្រង ដឹកនាំ សម្របសម្រួល និងតាមដានវាយតម្លៃការឆ្លើយតបនឹង

ការរាលដាលមេរោគអេដស៍ ហើយធ្វើរបាយការណ៍វឌ្ឍនភាពមកអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. មួយខែមុនកិច្ចប្រជុំពេញអង្គនីមួយៗ ៖

- រៀបចំឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តដំណើរការទៀងទាត់ជាប្រចាំក្នុងការគ្រប់គ្រងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- រៀបចំឱ្យមានផែនការយុទ្ធសាស្ត្រពហុវិស័យរាជធានី ខេត្ត និងផែនការថវិកាប្រចាំឆ្នាំប្រយុទ្ធនឹងជំងឺអេដស៍ និងវិភាជថវិកាសម្រាប់អនុវត្តការងារ។
- ដាក់បញ្ចូលតំណាងនៃបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ហ្វុនប៉ាម និងឌីហ្វុនប៉ាម (FoNPAM & DFoNPAM) ទៅក្នុងយន្តការឆ្លើយតបនឹងមេរោគអេដស៍រាជធានីខេត្ត ក្រុង ខណ្ឌ ស្រុក ជាមួយនឹងភារកិច្ចច្បាស់លាស់ក្នុងការរួមចំណែកគាំទ្រដល់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសការងារតាមដានវាយតម្លៃ។

ថ្ងៃពុធ ៦រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

**ប្រធានអង្គប្រជុំ**

**ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**